# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## អំពីពាក្យថាឯករាជ្យតាមផ្លូវលោកនិងតាមផ្លូវធម៌

Website: www.hoksavann.org

ថ្ងៃទី២៨ វិច្ឆិកា ២០០៨

### ១- អំពីពាក្យឯករាជ្យតាមផ្លូវលោក ៖

ពាក្យថាឯករាជ្យតាមផ្លូវលោក បើតាមវចនានុក្រមខ្មែរឲ្យដឹងថា ភាពនៃរដ្ឋឬប្រទេសដែលមានសិទ្ធិនិងសេរីភាពពេញបរិបូណ៌ ក្នុងការគ្រប់គ្រងខ្លួនឯង ពុំចំណុះប្រទេសដទៃ គឺគ្រប់គ្រងឯករាជ្យការពារឯករាជ្យខ្លួនឯងបាន ។ បើយកន័យខ្លះតាមវចនានុក្រមពួកបស្ចឹមប្រទេសថា សេរីភាពរបស់រដ្ឋនីមួយៗ គ្រប់គ្រងឬត្រួតត្រាដោយខ្លួនឯង ឈរលើខ្លួនឯងបានគ្មានចំណុះប្រទេសណា ។ ដូច្នេះការឲ្យន័យមានប្រភពផ្សេងគ្នា ប៉ុន្តែមានន័យដូចគ្នា គឺពាក្យថាឯករាជ្យ បានដល់ប្រទេសដែលមានអំណាចខ្លួនឯង គ្មានប្រទេសណាធ្វើអាណានិគមនិយមត្រួតត្រាពីលើខ្លួន

### ២- ឯករាជ្យតាមផ្លូវធម៌ ៖

ពាក្យថាឯករាជ្យតាមន័យផ្លូវធម៌របស់ព្រះពុទ្ធសាសនា បានដល់ការផ្ដាច់ចិត្តចេញពីឧបក្កិលេសគ្រឿងសៅហ្មងរបស់ចិត្ត ឲ្យចិត្តឯករាជ្យ ព្រោះថា បើចិត្តមានឧបក្កិលេសជាចិត្តគ្មានឯករាជ្យទេ ព្រោះឧបក្កិលេសនេះដឹកនាំចិត្តឲ្យធ្វើអំពើអាក្រក់ផ្សេងៗ ទៅតាមសភាពរបស់ឧបក្កិលេស ដែលមានឥទ្ធិពលមានអំណាចទៅលើផ្លូវចិត្ត ។ ចិត្តដែលបានឯករាជ្យដំកល់ក្នុងកុសលធម៌មកពីគ្មានឧបក្កិលេសត្រួតត្រាពីលើចិត្ត ។ ចិត្តនៅមានកិលេសតណ្ហាបញ្ជាពីលើ ពុំឈ្មោះថាចិត្តមានឯករាជ្យទេ គឺចិត្តជាខ្ញុំនៃតណ្ហា ចិត្តនៅក្រោមបង្គាប់របស់តណ្ហា ។ ចិត្តដែលបានទទួលឯករាជ្យពេញបរិបូណ៌ គឺលោកុត្តរចិត្ត ជាចិត្តរំដោះខ្លួនចេញពីតណ្ហារហូតបានសំរេចព្រះនិព្វាន ។

### ៣- ទំនាក់ទំនងឯករាជ្យផ្លូវលោកនិងផ្លូវធម៌ ៖

ប្រវត្តិសាស្ត្របញ្ជាក់ថា ការបាត់បង់ឯករាជ្យរហូតបាត់បង់ទឹកដី ឬទឹកដីរួមតូចកាលពីជំនាន់ដើមរហូតមកដល់បច្ចុប្បន្ននៃប្រទេសខ្លះ ដូចជាប្រទេសកម្ពុជាជាដើម មកអំពីការគ្រប់គ្រងប្រទេសធ្វេសប្រហែសពុំបានប្រុងប្រយ័ត្ន កើតមានការបែកបាក់សាមគ្គីផ្ទៃក្នុងពុំមានឯកភាពជាតិ ។ ការបែកបាក់ផ្ទៃក្នុងជាកត្តាចំបង ដែលនាំឲ្យបាត់បង់ឯករាជ្យឬអធិបតេយ្យជាតិ ហើយជាកត្តានាំឲ្យអស់ទឹកដីរបស់ខ្លួន ព្រោះបរទេសដែលអាចលូកដៃចូលមកឈ្លានពានប្រទេសណាមួយបាន ភាគច្រើនដោយការបែកបាក់ផ្ទៃក្នុង ។ ក្នុងន័យនេះ ទំនាក់ទំនងផ្លូវធម៌ គឺអ្នកដឹកនាំមានមហិច្ឆិតាផ្ទាល់ខ្លួន កាន់លទ្ធិផ្ដាច់ការសង្កត់សង្កិនអ្នកស្លូតត្រង់ ដែលជាប្រជាពលរដ្ឋរបស់ខ្លួន ដោយអំពើអយុត្តិធម៌ ធ្វើឲ្យប្រជាពលរដ្ឋក្ដៅក្រហាយប្រឆាំងតបវិញ អ្នកមានអំណាចគ្មានសមត្ថភាពទប់ទល់បាន ក៏ទៅពឹងបរទេសឲ្យមកជួយបង្ក្រាប ។ បើការបង្ក្រាបនោះមានជ័យជំនះ ហើយបើប្រទេសដែលជួយច្បាំងនោះមានមហិច្ឆិតាផង ក៏ធ្វើអាណានិគមនិយមលើប្រទេសខ្លួនទៅ ឯករាជ្យក៏ត្រូវបាត់បង់ ។ នេះមកអំពីអ្នកដឹកនាំប្រាសចាកផ្លូវធម៌ បណ្ដោយឲ្យមហិច្ឆិតាឬតណ្ហារបស់ខ្លួនដឹកនាំរហូតបាត់បង់ឯករាជ្យ ។ បើគោរពសិទ្ធិរបស់ប្រជាពលរដ្ឋឲ្យបានពេញលេញ នោះសាមគ្គីនឹងកើតមាន ហើយបរទេសទោះបីមានមហិទ្ធិឫទ្ធិខ្លាំងក្លាយ៉ាងណា ក៏ពុំហ៊ានចូលឈ្លានពាន ប្រទេសខ្លួនបានឯករាជ្យក៏ស្ថិតនៅគង់វង់ ។ល។

❑